Australian Government
Australian Taxation Office

# ជំនួយសម្រាប់ការធ្វើរបាយការណ៍ពន្ធដារលើកដំបូងរបស់លោកអ្នក

**ទើបមកដល់ប្រទេសអូស្ត្រាលីថ្មីថ្មោងមែនទេ? Australian Taxation Office (ATO) អាចជួយលោកអ្នកពេលលោកអ្នកធ្វើរបាយការណ៍ពន្ធដារលើកដំបូង។**

## តើនរណាត្រូវដាក់ពាក្យរបាយការណ៍ពន្ធដារ?

បណ្ដាជនភាគច្រើនត្រូវបំពេញរបាយការណ៍ពន្ធដារ ហើយដាក់ពាក្យ (lodge) វាជាមួយនឹង ATO រាល់ឆ្នាំ។

## ហេតុអ្វីបានជាខ្ញុំត្រូវតែដាក់ពាក្យរបាយការណ៍ពន្ធដារ?

ATO ត្រូវដឹងថាតើលោកអ្នករកប្រាក់បាន (ប្រាក់ចំណូល) ប៉ុន្មាននៅក្នុងអំឡុងពេលឆ្នាំសារពើពន្ធ ហើយនិងចំណាយកាត់បន្ថយចំណូល (deductions) ដែលលោកអ្នកអាចទាមទារវិញ។ ព័ត៌មាននេះប្រាប់ទៅពួកគេថាតើលោកអ្នកត្រូវបង់ពន្ធដារបន្ថែម (វិក្កយបត្រពន្ធដារ - a tax bill) ឬក៏លោកអ្នកត្រូវបានទទួលប្រាក់វិញ (ប្រាក់ពន្ធដែលរដ្ឋសងវិញ - a tax refund)។

ឆ្នាំសារពើពន្ធគឺពីថ្ងៃទី១ ខែកក្កដា ដល់ថ្ងៃទី៣០ ខែមិថុនា។

## តើពេលណាខ្ញុំត្រូវដាក់ពាក្យរបាយការណ៍ពន្ធដាររបស់ខ្ញុំ?

បណ្ដានិយោជក, ធនាគារ និងអង្គការអាជីវកម្មដទៃទៀតផ្ដល់ឲ្យ ATO នូវព័ត៌មានលម្អិតអំពីបណ្ដាបុគ្គលិកនិយោជិតដែលពួកគេធ្វើការជាមួយ។ ប្រសិនបើលោកអ្នករង់ចាំដល់ចុងខែកក្កដា ATO ដាក់បញ្ចូលព័ត៌មានលម្អិតទាំងនេះនៅក្នុងរបាយការណ៍ពន្ធដារសម្រាប់លោកអ្នក។ ការធ្វើយ៉ាងនេះ ធ្វើឲ្យការដាក់ពាក្យរបាយការណ៍ពន្ធដាររបស់លោកអ្នកកាន់តែលឿន និងកាន់តែងាយស្រួល។

ប្រសិនបើលោកអ្នកធ្វើរបាយការណ៍ពន្ធដារដោយខ្លួនឯង, លោកអ្នកត្រូវដាក់ពាក្យឲ្យបានមុនថ្ងៃទី៣១ ខែតុលា រៀងរាល់ឆ្នាំ។
ប្រសិនបើភ្នាក់ងារពន្ធដារដែលបានចុះបញ្ជីឈ្មោះជួយលោកអ្នក លោកអ្នកត្រូវចាប់ផ្ដើមធ្វើការជាមួយពួកគេមុនថ្ងៃទី៣១ ខែតុលា។

## តើខ្ញុំដាក់ពាក្យរបាយការណ៍ពន្ធដារដោយរបៀបណា?

ប្រសិនបើលោកអ្នកធ្វើរបាយការណ៍ពន្ធដារដោយខ្លួនឯង លោកអ្នកអាចធ្វើការដាក់ពាក្យនៅលើអ៊ីនធើរណិតដោយប្រើ myTax។
ប្រសិនបើលោកអ្នកប្រើភ្នាក់ងារពន្ធដារដែលបានចុះបញ្ជីឈ្មោះ (registered tax agent) ដើម្បីដាក់ពាក្យរបាយការណ៍ លោកអ្នកគួរតែធ្វើការណាត់ជួបជាមួយនឹងពួកគេដើម្បីនិយាយពិគ្រោះ។

## តើព័ត៌មានអ្វីខ្លះដែលខ្ញុំត្រូវការសម្រាប់ធ្វើរបាយការណ៍ពន្ធដាររបស់ខ្ញុំ?

លោកអ្នកនឹងត្រូវការ៖

- tax file number (TFN)

- ព័ត៌មានលម្អិតនៃគណនីធនាគាររបស់លោកអ្នក ក្នុងករណីដែលគេត្រូវផ្ទេរប្រាក់ទៅឲ្យលោកអ្នកវិញ
- ប្រាក់ចំណូល - ដើម្បីបញ្ជាក់នូវចំនួនប្រាក់ទាំងឡាយដែលលោកអ្នករកបាន
  - របាយការណ៍ប្រាក់ចំណូលពីគ្រប់និយោជកទាំងអស់របស់លោកអ្នក
  - របាយការណ៍ប្រាក់ចំណូលសង្ខេបពី Centrelink
- ប្រាក់ចំណាយកាត់បន្ថយប្រាក់ចំណូល (deductions) និងចំណាយផ្សេងៗ - ដើម្បីបញ្ជាក់នូវការកាត់បន្ថយចំណាយផ្សេងៗដែលលោកអ្នកទាមទារវិញ
  - បង្កាន់ដៃសម្រាប់ចំណាយផ្សេងៗទាក់ទងនឹងការងារ, ការបរិច្ចាគ ឬអំណោយផ្សេងៗ

ប្រសិនបើលោកអ្នកដាក់ពាក្យរបាយការណ៍ពន្ធដាររបស់លោកអ្នកតាមអ៊ីនធើរណិតដោយប្រើ myTax លោកអ្នកនឹងត្រូវការលេខអត្តសញ្ញាណអ្នកប្រើ (user ID) និងពាក្យសម្ងាត់ (password) គណនី myGov របស់លោកអ្នក។ ប្រសិនបើលោកអ្នកគ្មានគណនី myGov ទេនោះ លោកអ្នកអាចបង្កើតវាបាន ហើយភ្ជាប់ទៅនឹង ATO នៅឯ my.gov.au (ជាភាសាអង់គ្លេស)។

## តើប្រាក់ចំណូលអ្វីខ្លះដែលខ្ញុំត្រូវប្រកបញ្ចូល?

លោកអ្នកត្រូវតែប្រកបញ្ចូលនូវរាល់ប្រាក់ចំណូលទាំងអស់ដែលលោកអ្នកទទួលបាននៅក្នុងអំឡុងឆ្នាំសារពើពន្ធ។ នេះមានន័យថា ប្រាក់ដែលលោកអ្នករកបានពីគ្រប់ការងារទាំងអស់ ដោយរួមទាំងពី៖

- ការងារពេញពេល (full time)
- ការងារមិនពេញពេល (part time)
- ការងារមិនជាប់លាប់ (casual) ឬកិច្ចការយូរៗម្តង(odd jobs)
- ការងារធ្វើការឲ្យខ្លួនឯង (self-employment)
- ការងារបានលុយសុទ្ធ (cash jobs)។

លោកអ្នកក៏ត្រូវប្រកបញ្ចូលផងដែរនូវប្រាក់ដែលរកបានតាមវិធីផ្សេងៗទៀត ដោយរួមមានពី៖

- សកម្មភាពអនឡាញ
- សេដ្ឋកិច្ចចែករំលែក
- សកម្មភាពរៃអង្គាសប្រាក់សម្រាប់គម្រោង ឬជំនួញ
- ប្រាក់ចំណូលសេវាកម្មផ្ទាល់ខ្លួន
- ប្រាក់ចំណូលពីបរទេស និងការវិនិយោគនៅក្រៅប្រទេស
- ការប្រាក់ពីគណនីធនាគារនានា
- ប្រាក់ឧបត្ថម្ភពីរដ្ឋាភិបាល (ឧទាហរណ៍ពី Centrelink)
- ការមានអចលនទ្រព្យជួលឲ្យគេ
- ប្រាក់ចំណេញតាមទីផ្សារភាគហ៊ុននានា។

ទោះជាលោកអ្នករកប្រាក់ចំណូលទាំងនោះដោយរបៀបណាក៏ដោយ ក៏ត្រូវចងចាំថា លោកអ្នកត្រូវប្រកបញ្ចូលវានៅក្នុងរបាយការណ៍ពន្ធដាររបស់លោកអ្នក។

## តើការចំណាយកាត់បន្ថយប្រាក់ចំណូលអ្វីខ្លះដែលខ្ញុំអាចទាមទារវិញ?

អ្នកប្រហែលអាចទាមទារប្រាក់ចំណាយសម្រាប់កាត់បន្ថយពន្ធសម្រាប់ការចំណាយមួយចំនួនដែលទាក់ទងនឹងការងាររបស់អ្នក។ ដើម្បីទាមទារប្រាក់ចំណាយសម្រាប់កាត់បន្ថយពន្ធសម្រាប់ការចំណាយ ទាក់ទងនឹងការងារ គឺមានបទបញ្ញត្តិចំនួនបីដែលអ្នកត្រូវការឆ្លើយតប៖

**ការបដិសេធការទទួលខុសត្រូវ៖** ព័ត៌មាននេះគឺគ្រាន់តែជាសេចក្តីសង្ខេបទូទៅមួយទេ ហើយនៅថ្មីនៅថ្ងៃទី 3ខែមិនា ឆ្នាំ 2023

លោកអ្នកអាចចម្លង កែសម្រួល កែប្រែ បញ្ជូន និងចែកចាយប័ណ្ណព័ត៌មាននេះដោយសេរីតាមបំណងរបស់លោកអ្នក (ក៏ប៉ុន្តែមិនមែនក្នុងវិធីមួយដែលបង្ហាញថា ATO ឬក៏ Commonwealth ផ្តល់ការយល់ព្រមដល់លោកអ្នក ឬក៏សេវា ឬផលិតផលណាមួយរបស់លោកអ្នកឡើយ)។

1. អ្នកត្រូវតែបានចំណាយប្រាក់ដោយខ្លួនអ្នក ហើយមិនបានទទួលប្រាក់សំណងមកវិញទេ
2. ការចំណាយនានាត្រូវតែទាក់ទងផ្ទាល់ទៅនឹងការរកប្រាក់ចំណូលរបស់អ្នក
3. អ្នកត្រូវតែមានកំណត់ត្រាដើម្បីបង្ហាញជាភស្តុតាង ជាធម្មតា (បង្កាន់ដៃ)

ចំណាយកាត់បន្ថយចំណូលទូទៅរួមមាន៖

- ចំណាយរថយន្ត និងចំណាយការធ្វើដំណើរ
- សម្លៀកបំពាក់, បោកគក់ និងបោកអ៊ុតស្ងួត
- ចំណាយផ្សេងៗទាក់ទងនឹងការិយាល័យនៅផ្ទះ (home office)
- ចំណាយផ្សេងៗទាក់ទងនឹងការអប់រំបំប៉នចំណេះខ្លួនឯង
- ឧបករណ៍(tools) និងសម្ភារៈប្រើ(equipment)។

លោកអ្នកអាចស្វែងរកព័ត៌មានបន្ថែមអំពីចំណាយកាត់បន្ថយចំណូល (deductions) ដែលលោកអ្នកអាចទាមទារវិញនៅលើវិបសាយថ៍របស់ ATO នៅឯ ato.gov.au/deductions (ជាភាសាអង់គ្លេស)។

លោកអ្នកត្រូវតែអាចបង្ហាញនូវបញ្ជីឯកសារ, ឧទាហរណ៍ បង្កាន់ដៃផ្សេងៗ សម្រាប់រាល់ចំណាយកាត់បន្ថយចំណូលដែលលោកអ្នកទាមទារវិញ។ លោកអ្នកត្រូវតែរក្សាទុកបញ្ជីឯកសារទាំងនេះសម្រាប់រយៈពេលយ៉ាងតិច៥ឆ្នាំ។ ATO  អាចស្នើសុំឲ្យលោកអ្នកបង្ហាញនូវបញ្ជីឯកសារទាំងនេះបាននៅគ្រប់ពេលវេលា។

## កន្លែងទៅរកជំនួយ

សម្រាប់ព័ត៍មានបន្ថែម សូមចូលទៅមើលវិបសាយថ៍របស់ ATO នៅឯ ato.gov.au/TaxTimeResources។

លោកអ្នកក៏អាចនិយាយជាមួយនឹងភ្នាក់ងារពន្ធដារដែលបានចុះបញ្ជីឈ្មោះដើម្បីសុំជំនួយផងដែរ។

## ធនធាននានា (ជាភាសាអង់គ្លេស)

- Income, deductions, offsets and records
- Deductions you can claim
- Your tax return
- Finding and using a tax practitioner
- Records you need to keep

## អត្ថន័យនៃពាក្យពន្ធដារ

- របាយការណ៍ពន្ធដារ (Tax return) – ហ្វមមួយដែលលោកអ្នកត្រូវបំពេញរាល់ឆ្នាំ ហើយបញ្ជូនទៅ ATO។ នៅលើហ្វមនោះ លោកអ្នកប្រាប់ទៅ ATO  នូវចំនួនប្រាក់ដែលលោកអ្នករកបាន ហើយនិងពន្ធដារដែលលោកអ្នកបានបង់រួចហើយ។
- ការដកចំណាយ (Deduction) - មានពេលខ្លះលោកអ្នកត្រូវទិញរបស់របរផ្សេងៗ (ដូចជាឧបករណ៍ ឬក៏សម្លៀកបំពាក់ពិសេស) ដើម្បីជួយលោកអ្នកបំពេញការងារលោកអ្នក។ ចំណាយលើរបស់របរទាំងនេះអាចត្រូវគេប្រើដើម្បីកាត់បន្ថយនូវចំនួនពន្ធដារដែលលោកអ្នកត្រូវបង់។ នេះគេហៅថា ចំណាយកាត់បន្ថយប្រាក់ចំណូល (a deduction)។
- ប្រាក់ចំណូល (Income) -  ចំនួនប្រាក់ដែលលោកអ្នករកបានពីការងារ, ការវិនិយោគទុន ឬការលក់ទ្រព្យសម្បត្តិផ្សេងៗ។
- ភ្នាក់ងារពន្ធដារ (Tax agent) - បុគ្គល ឬក៏ក្រុមហ៊ុនដែលលោកអ្នកបង់ប្រាក់កម្រៃដើម្បីជួយចាត់ចែងការងារពន្ធដារ ឬប្រាក់សោធននិវត្តន៍របស់លោកអ្នក។

**ការបដិសេធការទទួលខុសត្រូវ៖** ព័ត៍មាននេះគឺគ្រាន់តែជាសេចក្តីសង្ខេបទូទៅមួយទេ ហើយនៅថ្មីនៅថ្ងៃទី 3ខែមិនា ឆ្នាំ 2023

លោកអ្នកអាចចម្លង កែសម្រួល កែប្រែ បញ្ជូន និងចែកចាយប័ណ្ណព័ត៍មាននេះដោយសេរីតាមបំណងរបស់លោកអ្នក (ក៏ប៉ុន្តែមិនមែនក្នុងវិធីមួយដែលបង្ហាញថា ATO ឬក៏ Commonwealth ផ្តល់ការយល់ព្រមដល់លោកអ្នក ឬក៏សេវា ឬផលិតផលណាមួយរបស់លោកអ្នកឡើយ)។